# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៦

សវនាការលើភស្តុតាងលើសំណុំរឿង០០២ វគ្គទី២ បានដំណើរការក្នុងសប្តាហ៍ទីបីរបស់ខ្លួន នៅខណៈពេលដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប ដែលបានធ្វើសក្ខីកម្មក្នុងការជំនុំជម្រះនេះ មានដូចជា៖ លោកស្រី **អ៊ុំ សុផានី** ត្រូវបានចោទសួរនូវសំណួរជាច្រើនស្តីពីរឿងរ៉ាវអតីតកាលក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តាមរយៈសៀវភៅដែលបានបោះពុម្ពផ្សាយរបស់គាត់ ហើយនិងលោកស្រី **ជូ កែមឡុន** បានផ្តល់សក្ខីកម្មថា លោកស្រី ធ្លាប់បានឃើញដោយផ្ទាល់ពីការចុះទស្សនកិច្ចរបស់សហជនជាប់ចោទ នៅក្នុងការដ្ឋានស្រុកត្រាំកក់ ក្នុងឆ្នាំ១៩៧៧។ អង្គជំនុំជម្រះ ក៏បានចាប់ផ្តើមស្តាប់ផងដែរនូវសក្ខីកម្មរបស់សាក្សីមួយរូបដែលមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រី **ជាំង ស្រីមុំ** ស្តីពីបទពិសោធន៍របស់លោកស្រី ជុំវិញការរៀបការដោយបង្ខំ ដែលបានរៀបចំដោយកម្មាភិបាលខ្មែរក្រហម ក្នុងសហករណ៍ជនបទរបស់លោកស្រី។ សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានប្រឹងប្រែងប្រើប្រាស់សក្ខីកម្មទាំងបីខាងលើនេះ ដើម្បីធ្វើការតំណាងឲ្យការរស់នៅក្រោមអំពើឃោរឃៅ និងការគ្រប់គ្រងផ្តាច់ការ ដោយអាជ្ញាធរនៅក្នុងស្រុកត្រាំកក់ដែលត្រូវបានចាត់ទុកថាជា “ស្រុកគំរូ" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រុមមេធាវីការពារក្តី បានមានបំណងធ្វើការឆ្លើយតបទៅនឹងការចោទប្រកាន់ទាំងនេះ តាមរយៈការធ្វើឲ្យលែងជឿជាក់លើព័ត៌មានគន្លឹះសំខាន់ៗចេញពីសេចក្តីថ្លែងការណ៍របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ របៀបនៃការតាំងសំណួរដេញដោលធ្វើឡើងដោយលោក **វ៉ិចទ័រ កូប៉េ** ដែលជាមេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** បានជីកយកព័ត៌មានយ៉ាងស៊ីជម្រៅជាងសហភាតារបស់គាត់ទៅទៀត ដោយសារតែគាត់បានសួរដេញដោល

ចំពោះរឿងរ៉ាវលម្អិតផ្ទាល់ខ្លួនដ៏សំខាន់បំផុតស្តីពីបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានបញ្ជាក់កន្លងមក រួមមាន៖ អសមត្ថភាពរបស់ស្រ្តីដែលជាម្តាយក្នុងការចិញ្ចឹមកូនរបស់គាត់ដែលបានស្លាប់ទៅហើយ និងការអះអាងរបស់ប្រជាជនផ្សេងទៀតដែលបញ្ជាក់ថាធ្លាប់ត្រូវបានបង្ខំឲ្យរៀបការ។ យុទ្ធសាស្រ្តរបស់លោក **កូប៉េ** ក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី បានធ្វើឲ្យមានជំទាស់តវ៉ាជាច្រើនបានកើតឡើងពីសំណាក់សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយការជំទាស់ទាំងនេះ ក៏បានទាមទារឲ្យមានការធ្វើអន្តរាគមន៍ពីសំណាក់ចៅក្រមជាច្រើនលើកច្រើនសាផងដែរ។ របាយការណ៍នេះ ធ្វើការវិភាគនូវបញ្ហាផ្លូវច្បាប់ និងនីតិវិធីនានា ធ្វើការសង្ខេបលើសក្ខីកម្មប្រចាំសប្តាហ៍ និងធ្វើការត្រួតពិនិត្យលើការគ្រប់គ្រងកិច្ចដំណើរនីតិវិធីសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ មេយូរី អានូភិនឌី (Mayuri Anupindi), ហ៊ុយ សម្បូណ៌, ឡូញ ង៉ែត, ដាញ៉ែល ម៉ាតថេស៍ (Daniel Mattes), ក្លែរ អ៊ឹម.ស៊ី ម៉ូឡិន (Claire McMullen), តាយ លីណា, ឡូស៊ី ស៊ូលីវ៉ាន់(Lucy Sullivan), ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដាសម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានា ក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University